វិទ្យាស្ថានជាតិអប់រំ
National Institute of Education

# សន្និសីទស្រាវជ្រាវថ្នាក់ជាតិលើកទី១ ឆ្នាំ២០២៦

## ការបង្ហាញលទ្ធផលស្រាវជ្រាវ

### ប្រធានបទ៖

# ប្រសិទ្ធភាពនៃការអនុវត្តអភិបាលកិច្ចរបស់នាយកសាលា ឆ្លើយតបការអប់រំឌីជីថលនៅមធ្យមសិក្សាទុតិយភូមិក្នុងស្រុកបាទីខេត្តតាកែវ


ធ្វើបទបង្ហាញដោយ៖ លោក ហេង ធីតា
អតីតនិស្សិតវគ្គនាយកជំនាន់ទី៧


ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៦

# មាតិកា

1. សេចក្តីផ្តើម
2. គោលបំណងនៃការស្រាវជ្រាវ
3. សំណួរស្រាវជ្រាវ
4. វិធីសាស្ត្រស្រាវជ្រាវ
5. លទ្ធផលស្រាវជ្រាវ និងពិភាក្សា
6. សេចក្តីសន្និដ្ឋាន និងសំណូមពរ

# ១.សេចក្តីផ្តើម

- ក្រសួងអប់រំ យុវជន និងកីឡា (២០១៧) បានកំណត់គោលបំណងយ៉ាងច្បាស់ទៅលើនាយកសាលា ដោយបានដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តិដូចជាគោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ អភិបាលកិច្ចស្តង់ដានាយកសាលា សម្រាប់លើកកម្ពស់គុណភាពអប់រំ។

- វិមជ្ឈការសាលារៀនគឺជា ការអនុវត្តនូវការគ្រប់គ្រងរដ្ឋបាលតាមបែបផែនអភិបាលកិច្ចល្អប្រកបដោយការទទួលខុសត្រូវ សាលារៀនមានការអភិវឌ្ឍ និងសាលារៀនមានលទ្ធភាពក្នុងការផ្តល់សេវាអប់រំជូនប្រជាពលរដ្ឋមូលដ្ឋាន ធានាឱ្យប្រាកដថាគុណភាពអប់រំមានភាពប្រសើរឡើង ជះផលវិជ្ជមានដល់លទ្ធផលសិក្សារបស់សិស្សានុសិស្ស។

- ការអនុវត្តអភិបាលកិច្ចរបស់នាយកសាលាដែលមិនបានផ្តល់នូវការចូលរួម និងគ្មានគណនេយ្យភាពនាំឱ្យការគ្រប់គ្រងការបង្រៀននិងរៀនពុំទទួលបានលទ្ធផលល្អនោះទេ

- ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងសាលារៀនឱ្យមានប្រសិទ្ធភាព មិនត្រឹមតែអាស្រ័យលើហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាប៉ុណ្ណោះទេ ប៉ុន្តែត្រូវការការដឹកនាំ និងអភិបាលកិច្ចសាលារៀនដែលមានប្រសិទ្ធភាពផងដែរ

- ដូចដែលបានរៀបរាប់ខាងលើទើបខ្ញុំបាទធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទ “ប្រសិទ្ធភាពនៃការអនុវត្តអភិបាលកិច្ចរបស់នាយកសាលា ឆ្លើយតបការអប់រំឌីជីថលនៅមធ្យមសិក្សាទុតិយភូមិក្នុងស្រុកបាទីខេត្តតាកែវ”។

## ២. គោលបំណងស្រាវជ្រាវ

១) សិក្សាពីប្រសិទ្ធិភាពនៃការអនុវត្តអភិបាលកិច្ចរបស់នាយក នៅមធ្យមសិក្សាទុតិយភូមិក្នុងស្រុកបាទីខេត្តតាកែវ

២) ឈ្វេងយល់ពីការអនុវត្តអភិបាលកិច្ចរបស់នាយកសាលាបានជំរុញការអប់រំឌីជីថលនៅមធ្យមសិក្សាទុតិយភូមិក្នុងស្រុកបាទីខេត្តតាកែវ

# ៣. សំណួរត្រាវជ្រាវ

១) តើការអនុវត្តអភិបាលកិច្ចរបស់នាយក នៅមធ្យមសិក្សាទុតិយភូមិក្នុងស្រុកបាទីខេត្តតាកែវមានប្រសិទ្ធភាពយ៉ាងដូចម្តេចខ្លះ?

២) តើការអនុវត្តអភិបាលកិច្ចរបស់នាយកសាលា នៅមធ្យមសិក្សាទុតិយភូមិក្នុងស្រុកបាទីខេត្តតាកែវបានជំរុញការអប់រំឌីជីថលយ៉ាងដូចម្តេចខ្លះ?

# ៤. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

| គោលបំណង | ឧបករណ៍ស្រាវជ្រាវ | ចំនួនភាគសំណាក | វិភាគទិន្នន័យ |
|---|---|---|---|
| សិក្សាពីប្រសិទ្ធិភាពនៃការអនុវត្តអភិបាលកិច្ចរបស់នាយក នៅមធ្យមសិក្សាទុតិយភូមិក្នុងស្រុកបាទីខេត្តតាកែវ | – កម្រងសំណួរ<br>– គណៈគ្រប់គ្រង<br>– គ្រូបង្រៀន | – គណៈគ្រប់គ្រង (n=២០)<br>– គ្រូបង្រៀន (n=១២៨) | – គម្លាតស្តង់ដា (Standard Deviation)<br>– មធ្យមភាគពិន្ទុ (Mean)<br>– កម្រិតចង្អុលបង្ហាញះពី(១) ដល់(៥) |
| ឈ្វេងយល់ពីការអនុវត្តអភិបាលកិច្ចរបស់នាយកសាលាបានជំរុញការអប់រំ ឌីជីថលនៅមធ្យមសិក្សាទុតិយភូមិក្នុងស្រុកបាទីខេត្តតាកែវ | – កម្រងសំណួរ<br>– គណៈគ្រប់គ្រង<br>– គ្រូបង្រៀន | – គណៈគ្រប់គ្រង (n=២០)<br>– គ្រូបង្រៀន (n=១២៨) | – គម្លាតស្តង់ដា (Standard Deviation)<br>– មធ្យមភាគពិន្ទុ (Mean)<br>– កម្រិតចង្អុលបង្ហាញះពី(១) ដល់(៥) |

# ៤.១ ការរៀបចំក្រម្រងសំណួរសម្រាប់ប្រមូលទិន្នន័យ

តើការអនុវត្តអភិបាលកិច្ចរបស់នាយកនៅមធ្យមសិក្សាទុតិយភូមិក្នុងស្រុកបាទីខេត្តតាកែវមានប្រសិទ្ធភាពយ៉ាងដូចម្តេចខ្លះ? (**មាន៥សមាសភាព៖៤០សូចនាករ**)




**ប្រសិទ្ធភាពនៃការអនុវត្តអភិបាលកិច្ចរបស់នាយក**

| ល.រ | បរិយាយ | កម្រិតចង្អុលបង្ហាញ | | | | |
|---|---|---|---|---|---|---|
| ក. តម្លាភាព (Transparency) | | ១ | ២ | ៣ | ៤ | ៥ |
| ១ | នាយកបានអនុវត្តផែនការអភិវឌ្ឍសាលារៀនស្របតាមគោលនយោបាយអប់រំ | | | | | |
| ២ | នាយកបានប្រើប្រាស់ទិន្នន័យពីប្រភពច្បាស់លាស់ដើម្បីធ្វើការសម្រេចចិត្ត | | | | | |
| ៣ | នាយកទទួលយកមតិយោបល់ពីគ្រប់ភាគីពាក់ព័ន្ធដើម្បីអភិវឌ្ឍន៍សាលារៀន | | | | | |
| ៤ | នាយកបានលើកទឹកចិត្តដល់គំនិតច្នៃប្រឌិត ដើម្បីជំរុញវិជ្ជាជីវៈរបស់គ្រូបង្រៀន | | | | | |
| ៥ | នាយកបានផ្តល់ឱកាសដល់សិស្សានុសិស្សគ្រប់រូប ទទួលបានការអប់រំ | | | | | |

**ការអនុវត្តអភិបាលកិច្ចរបស់នាយក បានជំរុញការអប់រំឌីជីថល**

| ល.រ | បរិយាយ | កម្រិតចង្អុលបង្ហាញ | | | | |
|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ |
| ១ | អាចចែករំលែកពីសារៈសំខាន់នៃចក្ខុវិស័យរបស់សាលារៀនដល់ភាគីពាក់ព័ន្ធតាមរយៈបណ្តាញសង្គម | | | | | |
| ២ | អាចបញ្ជៀបការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀននិងរៀន | | | | | |
| ៣ | មានបណ្តាញទំនាក់ទំនងសង្គមជាមួយសហគមន៍ | | | | | |
| ៤ | មានធនធានរូបវន្តបច្ចេកវិទ្យា អ៊ីនធឺណិត គាំទ្រដល់ការអប់រំស្នែម | | | | | |
| ៥ | ផ្តល់សុវត្ថិភាពក្នុងការរក្សាទុកទិន្នន័យសាលារៀនតាមបច្ចេកវិទ្យា | | | | | |

តើការអនុវត្តអភិបាលកិច្ចរបស់នាយកសាលា នៅមធ្យមសិក្សាទុតិយភូមិក្នុងស្រុកបាទីខេត្តតាកែវបានជំរុញការអប់រំឌីជីថលយ៉ាងដូចម្តេចខ្លះ? (**មាន១៤សូចនាករ**)

**៥.១ លទ្ធផលសំណួរស្រាវជ្រាវទី១៖** តើការអនុវត្តអភិបាលកិច្ចរបស់នាយក នៅមធ្យមសិក្សាទុតិយភូមិក្នុងស្រុកបាទីខេត្តតាកែវមានប្រសិទ្ធភាពយ៉ាងដូចម្តេចខ្លះ?

| ល.រ | សមាសភាព | មធ្យមភាគសរុប | | |
|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចម្លើយបញ្ជាក់ |
| ១ | តម្លាភាព | ៤.៣១ | ០.៦៣ | យល់ស្របខ្លាំង |
| ២ | ការចូលរួម | ៤.៣៣ | ០.៦២ | យល់ស្របខ្លាំង |
| ៣ | ស្វ័យភាព | ៤.១៩ | ០.៦៣ | យល់ស្រប |
| ៤ | ទំនួលខុសត្រូវ | ៤.២០ | ០.៦៥ | យល់ស្រប |
| ៥ | គណនេយ្យភាព | ៤.១៧ | ០.៧០ | យល់ស្រប |

# ពិភាក្សាលើសំណួរស្រាវជ្រាវទី១

- តាមរយៈលទ្ធផលបង្ហាញថា សមាសភាព "ការចូលរួម" ទទួលបានមធ្យមភាគពិន្ទុខ្ពស់បំផុត (មធ្យមភាគពិន្ទុ=៤.៣៣) ឋិតក្នុងកម្រិត "យល់ស្របខ្លាំង"។
- មធ្យមភាគពិន្ទុទាបបំផុតគឺ "គណនេយ្យភាព"(មធ្យមភាគពិន្ទុ=៤.១៧) ឋិតក្នុងកម្រិត "យល់ស្រប"។

# ពិភាក្សាលើសំណួរស្រាវជ្រាវទី១៖ គណនេយ្យភាព

- បិទផ្សាយបញ្ជីចំណូលក្នុងសាលារៀនដល់ភាគីពាក់ព័ន្ធ (មធ្យមភាគពិន្ទុ=៣.៦៨) ឋិតក្នុងកម្រិត "យល់ស្រប"។
- វាយតម្លៃលើលទ្ធផលការងារដោយស្មើភាព (មធ្យមភាគពិន្ទុ=៤.២០) ឋិតក្នុងកម្រិត "យល់ស្រប"។
- ជំរុញការផ្សព្វផ្សាយព័ត៌មានតាមរយៈបណ្តាញសង្គម (មធ្យមភាគពិន្ទុ=៤.២០) ឋិតក្នុងកម្រិត "យល់ស្រប"។

# ពិភាក្សាលើសំណួរស្រាវជ្រាវទី១៖ គណនេយ្យភាព

- យោងតាម Fullan (2020). គណនេយ្យភាព (Accountability) ត្រូវបានចាត់ទុកជាធាតុសំខាន់មួយនៃ អភិបាលកិច្ចសាលា ដែលជួយធានាឱ្យការគ្រប់គ្រងរបស់នាយកសាលាមានតម្លាភាព ប្រសិទ្ធភាព និងអាចឆ្លើយតបទៅនឹងការផ្លាស់ប្តូរបច្ចេកវិទ្យាបានទាន់ពេលវេលា។
- យោងតាម UNESCO (2023). ការពង្រឹងគណនេយ្យភាពក្នុងការអប់រំឌីជីថលអាចអនុវត្តបានតាមរយៈការកំណត់តួនាទី និងភារកិច្ចច្បាស់លាស់សម្រាប់គ្រូបង្រៀន បុគ្គលិក និងផ្នែកបច្ចេកវិទ្យា ព្រមទាំងការបង្កើតប្រព័ន្ធតាមដាន និងវាយតម្លៃការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀន និងគ្រប់គ្រងសាលា។

# ពិភាក្សាលើសំណួរស្រាវជ្រាវទី១៖ គុណនេយ្យភាព

- យោងតាម OECD (2015). ក៏បានបញ្ជាក់ថា ការប្រើប្រាស់ប្រព័ន្ធទិន្នន័យឌីជីថល និងការវាយតម្លៃ លទ្ធផលជាប្រចាំ គឺជាមធ្យោបាយសំខាន់ក្នុងការបង្កើនគណនេយ្យភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងសាលារៀនក្នុងយុគសម័យឌីជីថល។
- យោងតាម UNESCO (2023). ការគ្រប់គ្រងអប់រំក្នុងសម័យឌីជីថល ត្រូវការប្រព័ន្ធគណនេយ្យភាព ដែលអាចធានាបាននូវតម្លាភាព ការវាស់វែងលទ្ធផល និងការទទួលខុសត្រូវចំពោះការប្រើប្រាស់បច្ចេកវិទ្យាក្នុងការអប់រំ។

## ៥.២ លទ្ធផលសំណួរស្រាវជ្រាវទី២៖ តើការអនុវត្តអភិបាលកិច្ចរបស់នាយកសាលានៅមធ្យមសិក្សាទុតិយភូមិក្នុងស្រុកបាទីខេត្តតាកែវបានជំរុញការអប់រំឌីជីថលយ៉ាងដូចម្ដេចខ្លះ?

| ល.រ | សូចនាករ | មធ្យមភាគសរុប | | |
|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
| ១ | អាចចែករំលែកពីសារៈសំខាន់នៃចក្ខុវិស័យរបស់សាលារៀនដល់ភាគីពាក់ព័ន្ធតាមរយៈបណ្ដាញសង្គម | ៣.៧៩ | ០.៧៧ | យល់ស្រប |
| ២ | អាចបញ្ចៀបការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀននិងរៀន | ៣.៨៥ | ០.៧៦ | យល់ស្រប |
| ៣ | មានបណ្ដាញទំនាក់ទំនងសង្គមជាមួយសហគមន៍ | ៤.០៧ | ០.៦១ | យល់ស្រប |
| ៤ | មានធនធានរូបវន្តបច្ចេកវិទ្យា អ៊ីនធឺណិត គាំទ្រដល់ការអប់រំស្នែម | ៣.៦២ | ០.៨៤ | យល់ស្រប |
| ៥ | ផ្តល់សុវត្ថិភាពក្នុងការរក្សាទុកទិន្នន័យសាលារៀនតាមបច្ចេកវិទ្យា | ៣.៩៧ | ០.៧០ | យល់ស្រប |
| ៦ | ជំរុញឱ្យគ្រូបង្រៀនប្រើប្រាស់ឧបករណ៍ឌីជីថលក្នុងការបង្រៀនឱ្យស្របតាមគោលនយោបាយអប់រំស្នែម | ៤.០៨ | ០.៦១ | យល់ស្រប |
| ៧ | ជំរុញឱ្យគ្រូបង្រៀនស្រាវជ្រាវឯកសារមេរៀនបន្ថែម តាមរយៈប្រព័ន្ធអ៊ីនធឺណិត | ៤.២៩ | ០.៦៤ | យល់ស្របខ្លាំង |

| | | | | |
|---|---|---|---|---|
| ៨ | លើកទឹកចិត្តឱ្យគ្រូបង្រៀនផលិតមាតិកាឌីជីថលឱ្យបានច្រើន | ៤.០៦ | ០.៦៧ | យល់ស្រប |
| ៩ | ជំរុញឱ្យគ្រូ និងអាណាព្យាបាលអាចទំនាក់ទំនងគ្នា ដោយប្រើប្រាស់បណ្តាញសង្គម | ៤.៣២ | ០.៦៦ | យល់ស្របខ្លាំង |
| ១០ | លើកទឹកចិត្តសិស្សក្នុងការរៀនជាមួយនឹងការប្រើប្រាស់ឧបករណ៍ឌីជីថល | ៤.១៣ | ០.៦២ | យល់ស្រប |
| ១១ | អាចទទួលបានមតិកែលម្អទាន់ពេលវេលា តាមរយៈវេទិកាឌីជីថល | ៣.៩៦ | ០.៦៦ | យល់ស្រប |
| ១២ | អាចពិនិត្យតាមដានដំណើរការសិក្សារបស់សិស្សានុសិស្សតាមរយៈឧបករណ៍ឌីជីថល | ៣.៨៨ | ០.៦៦ | យល់ស្រប |
| ១៣ | ជំរុញឱ្យសិស្ស និងគ្រូបង្រៀន អាចចូលប្រើឧបករណ៍ ឌីជីថលនៅក្នុងបណ្ណាល័យ | ៣.៧៩ | ០.៧២ | យល់ស្រប |
| ១៤ | អាចពង្រីកបណ្តាញវិជ្ជាជីវៈ តាមរយៈថ្នាលឌីជីថលនានា | ៣.៧៩ | ០.៦៨ | យល់ស្រប |

# ពិភាក្សាលើសំណួរស្រាវជ្រាវទី២

- តាមរយៈលទ្ធផលបង្ហាញថា សមាសភាព "ជំរុញឱ្យគ្រូបង្រៀនស្រាវជ្រាវឯកសាររមេរៀនបន្ថែមតាមរយៈប្រព័ន្ធអ៊ីនធឺណិត" ទទួលបានមធ្យមភាគពិន្ទុខ្ពស់បំផុត (មធ្យមភាគពិន្ទុ=៤.២៩)ឋិតក្នុងកម្រិត "យល់ស្របខ្លាំង"។
- មធ្យមភាគពិន្ទុទាបបំផុតគឺ "មានធនធានរូបវន្តបច្ចេកវិទ្យា អ៊ីនធឺណិត គាំទ្រដល់ការអប់រំស្វែម"(មធ្យមភាគពិន្ទុ=៣.៦២) ឋិតក្នុងកម្រិត "យល់ស្រប"។

## ពិភាក្សាលើសំណួរស្រាវជ្រាវទី២៖ ធនធានរូបវន្តបច្ចេកវិទ្យា អ៊ីនធឺណិត

- យោងតាម OECD (2023). ក្នុងបរិបទនៃការផ្លាស់ប្តូរទៅកាន់ការអប់រំឌីជីថល (Digital Education) ការអនុវត្តអភិបាលកិច្ចរបស់នាយកសាលាឱ្យមានប្រសិទ្ធភាព មិនអាចខ្វះធនធានរូបវន្តបច្ចេកវិទ្យាបានទេ។ ធនធានទាំងនេះ គឺជាមូលដ្ឋានសំខាន់សម្រាប់គាំទ្រការគ្រប់គ្រង ការបង្រៀន និងការរៀនតាមបែបឌីជីថល។
- យោងតាម World Bank (2025). ធនធានរូបវន្តបច្ចេកវិទ្យា គឺជាកត្តាសំខាន់មួយដែលជួយគាំទ្រប្រសិទ្ធភាពនៃការអនុវត្តអភិបាលកិច្ចរបស់នាយកសាលា ក្នុងការឆ្លើយតបនឹងការអប់រំឌីជីថលនៅវិទ្យាល័យសាធារណៈ។

# ពិភាក្សាលើសំណួរស្រាវជ្រាវទី២៖ ធនធានរូបវន្តបច្ចេកវិទ្យា អ៊ីនធឺណិត

- យោងតាម UNESCO (2023). ធនធានរូបវន្តបច្ចេកវិទ្យា រួមមានឧបករណ៍ ICT ដូចជាកុំព្យូទ័រ Laptop Projector Smart TV Tablet និងបន្ទប់កុំព្យូទ័រ ដែលជួយឱ្យគ្រូ និងសិស្សអាចអនុវត្តការសិក្សាតាមប្រព័ន្ធឌីជីថលបានយ៉ាងមានប្រសិទ្ធភាព។
- យោងតាម Trucano និង Hawkins (2022) សមធម៌ឌីជីថល និងការប្រើប្រាស់កម្មវិធីសិក្សាអនឡាញ ប្រសិនបើគ្មានការវិនិយោគលើអ៊ីនធឺណិតទេ នោះការគ្រប់គ្រងទិន្នន័យសាលារៀននឹងជួបហានិភ័យ។។

# ពិភាក្សាលើសំណួរស្រាវជ្រាវទី២៖ ធនធានរូបវន្តបច្ចេកវិទ្យា អ៊ីនធឺណិត

- យោងតាម Hohlfeld et al., (2017). ការផ្ដល់ឧបករណ៍ និងអ៊ីនធឺណិតប្រកបដោយសមធម៌ គឺជាកត្តាកំណត់ដ៏ចម្បងក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។

---

- យោងតាម World Bank (2025). ក៏បានអះអាងថា ការវិនិយោគលើធនធានបច្ចេកវិទ្យាដូចជា Smart Classroom Computer Lab និងប្រព័ន្ធគ្រប់គ្រងព័ត៌មានសាលា មានឥទ្ធិពលវិជ្ជមានលើប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអប់រំឌីជីថល។ នាយកសាលាដែលមានសមត្ថភាពដឹកនាំ និងអាចគ្រប់គ្រងធនធានបច្ចេកវិទ្យាបានល្អ នឹងអាចជំរុញការផ្លាស់ប្ដូរឌីជីថលក្នុងសាលាបានយ៉ាងមានប្រសិទ្ធភាព

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

- ការអនុវត្តអភិបាលកិច្ចរបស់នាយក នៅមធ្យមសិក្សាទុតិយភូមិក្នុងស្រុកបាទីគឺមានប្រសិទ្ធភាព ។ ព្រមជាមួយគ្នាគណៈគ្រប់គ្រងសាលារៀនគួរយកចិត្តទុកដាក់លើការពង្រឹងគណនេយ្យភាពសាលារៀនឱ្យបានល្អប្រសើរ សំដៅជានាបាននិរន្តភាពនៃការចូលរួម និងស្មារតីភាពជាម្ចាស់ពីគ្រូបង្រៀន និងសហគមន៍។
- ការអនុវត្តអភិបាលកិច្ចរបស់នាយកបានជំរុញការអប់រំឌីជីថល៖ ធនធានរូបវន្តបច្ចេកវិទ្យា អ៊ីនធឺណិត គួរតែត្រូវបានបំពាក់ឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកប្រើប្រាស់ក្នុងដំណើរការរៀន និងបង្រៀន។

# សំណូមពរ

## ក្រសួងអប់រំ យុវជន និងកីឡា

- ជំរុញការអនុវត្តអភិបាលកិច្ចរបស់នាយកនៅតាមសាលាមធ្យមសិក្សាទុតិយភូមិ
- បន្តលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យា ក្នុងដំណើរការអនុវត្តវិធីសាស្ត្របង្រៀនរបស់គ្រូ

## មន្ទីរអប់រំ យុវជន និងកីឡា

- បង្កបរិយាកាសដល់សាលារៀនអនុវត្តនូវគណនេយ្យភាព និងតម្លាភាព
- បន្តជំរុញ និងលើកកម្ពស់ការអប់រំស្នែម

## សាលារៀន

- លើកកម្ពស់ និងផ្សារភ្ជាប់ការបង្រៀនដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល
- ជំរុញការអនុវត្តគណនេយ្យភាពសាលារៀន និងគៀរគរការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ

# សូមអរគុណ